## លោកអ្នកមិនមែនជាបុគ្គលតែម្នាក់ឯងទេ

SKYCITY នឹងលើកទឹកចិត្តលោកអ្នកឲ្យជ្រើសតាំងអ្នកប្រៀនប្រដៅសំរាប់ផ្គត់ផ្គង់ និងអ្នកវិជ្ជាជីវៈខាងផ្តល់ឱវាទណែនាំ ដើម្បីណែនាំ ហើយជួយលោកអ្នក។ យើងនឹងផ្តល់ដល់លោកអ្នកនូវបញ្ជីនៃកិច្ចបំរើផ្នែកឱវាទណែនាំដោយឥតគិតថ្លៃ រក្សាទុកជាសម្ងាត់ ហើយធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ។ គេក៏មានផ្តល់ជាភាសាខុសៗគ្នាយ៉ាងច្រើនផងដែរ។ លោកអ្នកក៏ត្រូវបានស្វាគមន៏ផងដែរ ឲ្យនាំជនណាម្នាក់ដែលអាចផ្គត់ផ្គង់លោកអ្នក នៅក្នុងការធ្វើសម្ភាសន៏ដកខ្លួនឯងចេញ។

# ខ្សែទូរស័ព្ទជំនួយលើ បញ្ហាល្បែងស៊ីសង

# 0800 654 655


SKYCITY Auckland 0800 SKYCITY (0800 759 2489)

SKYCITY Hamilton 07 834 4900

SKYCITY Queenstown 03 441 0400

SKYCITY Host Responsibility
អ៊ីម៉ែល: hostresponsibility@skycity.co.nz


# ការដកខ្លួនឯងចេញ នៅ SKYCITY

SKYCITY

Self Exclusion - Khmer

SKYCITY ទទួលមុខនាទីខុសត្រូវរបស់ខ្លួនក្នុងភាពជាអ្នកទទួលភ្ញៀវយ៉ាងហ្មត់ចត់ជាទីបំផុត៖ សុវត្ថិភាព និងសុខុមាលភាពនៃអតិថិជនរបស់យើងគឺជាអាទិភាពខ្ពស់បំផុត។ យើងក៏មានកាតព្វកិច្ចខាងផ្លូវច្បាប់ដ៏សំខាន់ផងដែរក្នុងភាពជាអ្នកបើកកាស៊ីណូ នៅក្រោមច្បាប់ល្បែងស៊ីសងញូវហ្សេឡង់ ឆ្នាំ២០០៣ (New Zealand Gambling Act 2003)។

ចំពោះមនុស្សខ្លះ ការលេងល្បែងស៊ីសងអាចបណ្តាលឲ្យមានការឈឺចាប់ មានរួមទាំងបញ្ហាប្រាក់កាស ការតានតឹងខាងផ្លូវចិត្ត និងការលំបាកកើតមាននៅក្នុងទំនាក់ទំនង។

ប្រសិនបើលោកអ្នក ឬនរណាម្នាក់ដែលលោកអ្នកស្គាល់កំពុងមានបញ្ហាដោយព្រោះការលេងល្បែងស៊ីសង នោះការដកខ្លួនឯងចេញអាចជាជំរើសល្អមួយ។

## តើការដកខ្លួនឯងជាអ្វី?

អតិថិជនអាចស្ម័គ្រចិត្តស្នើសុំដកខ្លួនឯងចេញពីកន្លែងលេងល្បែងស៊ីសងនៃគ្រប់ទាំង SKYCITY កាស៊ីណូនៅប្រទេសញូវហ្សេឡង់ សំរាប់រយៈពេល១ឆ្នាំ។

## តើការដកខ្លួនឯងគឺជាជំរើសតែមួយរបស់ខ្ញុំឬ?

ទេ – នេះគឺជាជំហានមួយនៃជំហានមួយចំនួនដែលលោកអ្នកអាចធ្វើបាន ដើម្បីគ្រប់គ្រងបញ្ហាល្បែងស៊ីសងរបស់លោកអ្នក មានរួមទាំងការធ្វើតាមគោលការណ៏លេងល្បែងស៊ីសងដែលមានការទទួលខុសត្រូវ និងការទទួលឱវាទណែនាំផ្នែកវិជ្ជាជីវៈ។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយខ្សែទូរស័ព្ទជំនួយលើបញ្ហាល្បែងស៊ីសង (Gambling Helpline): 0800 654 655 ឬមើលនៅតាមវិបសាយ www.gamblingproblem.co.nz។

## តើខ្ញុំអាចដកខ្លួនឯងចេញបែបណា?

ទៅជួបសមាជិកបុគ្គលិក SKYCITY ណាម្នាក់ ហើយប្រាប់គេថាលោកអ្នកចង់ដកខ្លួនឯងចេញពីកន្លែងលេងល្បែងស៊ីសង។

ប្រសិនបើលោកអ្នកមិនចង់អញ្ជើញមកកាន់កន្លែង SKYCITY ទេនោះ យើងនឹងផ្ញើជូនលោកអ្នកនូវពាក្យបំពេញការដកខ្លួនឯងចេញមួយច្បាប់ ដើម្បីឲ្យលោកអ្នកបំពេញនៅផ្ទះ រួចមកលោកអ្នកត្រូវផ្ញើមកឲ្យយើងវិញ ឬលោកអ្នកអាចទទួលយកពាក្យបំពេញនេះមួយច្បាប់បានពីអ្នកប្រឹក្សាលើបញ្ហាល្បែងស៊ីសង។

## តើមានទំរង់ការអ្វីខ្លះ?

ប្រសិនបើលោកអ្នកដកខ្លួនឯងចេញពីកន្លែងលេងល្បែងស៊ីសងនៅ SKYCITY សមាជិកបុគ្គលិកម្នាក់ដែលទទួលការហ្វឹកហ្វឺននឹងនៅប្រចាំការដើម្បីជួយលោកអ្នក ទោះថាពេលម៉ោងប៉ុន្មាននៅថ្ងៃនោះក្តី។ នៅក្នុងការប្រជុំនៅការិយាល័យឯកជននោះ គេនឹងកត់ត្រាទុកនូវព័ត៌មានលំអិតរបស់លោកអ្នក ហើយគេក៏នឹងថតយករូបរបស់លោកអ្នកផងដែរ។ គោលបំណងនៃការថតរូបទុកគឺដើម្បីជួយ SKYCITY សំគាល់រូបលោកអ្នក ប្រសិនបើលោកអ្នកសាកល្បងចូលមកលេងម្តងទៀតនៅកន្លែងលេងល្បែងស៊ីសង ក្នុងកាលដែលលោកអ្នកបានដកខ្លួនចេញ។

បន្ទាប់មក លោកអ្នកនឹងត្រូវគេលើកទឹកចិត្តឲ្យជ្រើសតាំងអ្នកប្រៀនប្រដៅ(គ្រួសារ /សមាជិកគ្រួសារ ឬមិត្តភក្តិ) ដែលគេអាចផ្គត់ផ្គង់លោកអ្នក ហើយដើម្បីជ្រើសរើសយកកិច្ចបំរើផ្តល់ឱវាទណែនាំ។ គេនឹងពន្យល់ប្រាប់លោកអ្នកអំពីល័ក្ខខ័ណ្ឌនៃការដកខ្លួនឯងចេញ មានរួមទាំងល័ក្ខខ័ណ្ឌនៃការសុំចូលលេងម្តងទៀត ដែលលោកអ្នកត្រូវបំពេញមុននឹងលោកអ្នកអាចត្រឡប់ចូលមកលេងម្តងទៀតនៅកន្លែងលេងល្បែងស៊ីសងរបស់ SKYCITY ក្នុងពេលណាមួយ។

ពេលនោះ គេនឹងចេញបញ្ជាឲ្យដកខ្លួនឯងចេញមួយច្បាប់ជូនលោកអ្នក។ នៅក្រោមបញ្ជានេះ លោកអ្នកត្រូវបានគេហាមឃាត់មិនឲ្យចូលទៅកន្លែងលេងល្បែងស៊ីសងនៅ SKYCITY Auckland, SKYCITY Hamilton និង SKYCITY Queenstown Casino សំរាប់រយៈពេលតិចបំផុត១ឆ្នាំ ហើយលុះត្រាតែលោកអ្នកបានបំពេញលើល័ក្ខខ័ណ្ឌនៃការសុំចូលលេងម្តងទៀតរបស់យើង។

ប្រសិនបើលោកអ្នកមានប័ណ្ណ Action លោកអ្នកអាចប្តូរយកពិន្ទុរបស់លោកអ្នកបាន។ ប័ណ្ណរបស់លោកអ្នកនៅពេលនោះត្រូវបានគេដាក់លែងឲ្យធ្វើការកើត។

## តើនេះគឺជារឿងរក្សាទុកជាសម្ងាត់ឬ?

ដំណើរការដកខ្លួនឯងចេញ គឺជាកិច្ចបំរើមួយធ្វើឡើងដោយមានការប្រុងប្រយ័ត្នជាទីបំផុតដែលបានចាត់ចែងឡើងឆ្ងាយផុតពីជាន់អាគារល្បែងស៊ីសង។ ព័ត៌មានដែលទទួលបានត្រូវបានរក្សាទុកជាសម្ងាត់។

## ចុះប្រសិនបើខ្ញុំផ្លាស់ប្តូរគំនិតរបស់ខ្ញុំ?

ថ្វីដ្បិតតែការដកខ្លួនឯងចេញធ្វើឡើងដោយស្ម័គ្រពីចិត្តក្តី កាលណាបញ្ជាឲ្យដកខ្លួនឯងចេញបានធ្វើហើយនោះ លោកអ្នកមិនអាចលុបវាចោលឡើយ។

## តើមានល័ក្ខខ័ណ្ឌការសុំចូលមកលេងម្តងទៀតអ្វីខ្លះ?

- មិនត្រូវឲ្យមានការបំពាននៃការដកខ្លួនឯងចេញ សំរាប់រយៈពេល៦ខែមុន ហើយនិង
- បង្ហាញឃើញភស្តុតាងថាលោកអ្នកបានទៅចូលរួមក្នុងកម្មវិធីផ្តល់ឱវាទណែនាំយ៉ាងតិចណាស់ចំនួន៦ដង។

កាលណាលោកអ្នកបានបំពេញល័ក្ខខ័ណ្ឌឲ្យចូលមកលេងម្តងទៀតហើយនោះ លោកអ្នកត្រូវការដាក់ពាក្យសុំជាផ្លូវការទៅ SKYCITY ដើម្បីសុំចូលមកលេងម្តងទៀត។ លោកអ្នកមិនអាចចូលមកកន្លែងលេងល្បែងស៊ីសងបានឡើយ រហូតទាល់តែ SKYCITY បានអនុញ្ញាតយល់ព្រមលើពាក្យសុំចូលមកលេងម្តងទៀតរបស់លោកអ្នក។ SKYCITY អាចជ្រើសរើសណែនាំដាក់បន្ថែមនូវល័ក្ខខ័ណ្ឌឲ្យចូលមកលេងម្តងទៀត ទៅតាមការសំរេចរបស់ខ្លួន។

## តើនឹងមានអ្វីកើតឡើងប្រសិនបើខ្ញុំសាកល្បងចូលមកកន្លែងលេងល្បែងស៊ីសង ក្នុងកាលខ្ញុំកំពុងដកខ្លួនឯងពីកន្លែងលេងល្បែងស៊ីសង?

លោកអ្នកអាចក្រសួងកិច្ចការផ្ទៃក្នុងកាត់ទោស ហើយផាកពិន័យ។ ប្រសិនបើត្រូវគេចាប់ខ្លួនបានលើសពី១ដង នោះលោកអ្នកនឹងត្រូវគេចេញឲ្យនូវលិខិត “ការតម្រូវឲ្យចាកចេញពីកន្លែងលេងល្បែងស៊ីសង” (RLTP) ឬចេញលិខិតល្មើសច្បាប់ (Trespass Notice)។ ការនេះនឹងមានន័យថាលោកអ្នកមិនអាចចូលមកកាន់ផ្នែកណាមួយនៃកន្លែង SKYCITY ដែលទាក់ទិននោះចំនួន២ឆ្នាំបន្ថែមទៀត។ ប្រសិនបើលោកអ្នកបំពាន លិខិតល្មើសច្បាប់ នោះលោកអ្នកអាចត្រូវប៉ូលិសញូវហ្សេឡង់កាត់ទោស។

## តើខ្ញុំនឹងនៅតែទទួលសម្ភារៈចុះផ្សាយពាណិជ្ជកម្មតាមសំបុត្រជាដដែលឬ?

ទេ។

## តើខ្ញុំនៅតែអាចទៅភោជនីយដ្ឋាន និងបារ(កន្លែងលក់ស្រា) ឬ?

ការដកខ្លួនឯងចេញ ហាមឃាត់លោកអ្នកមិនឲ្យចូលទៅកន្លែងលេងល្បែងស៊ីសង និងបារ ឬភោជនីយដ្ឋានណាមួយរបស់ SKYCITY នៅតាមកន្លែងទាំងនោះ។ នៅ SKYCITY Queenstown នេះមានរួមទាំងកន្លែងលេងទាំងមូល។ ទោះជាយ៉ាងណាក្តី លោកអ្នកនៅតែអាចទៅកន្លែងបារ ភោជនីយដ្ឋាន សណ្ឋាគារ និងមណ្ឌលប្រជុំទាំងឡាយនៅក្រៅកន្លែងលេងល្បែងស៊ីសងនៅ SKYCITY Auckland និង SKYCITY Hamilton។